# គន្លឹះការចិញ្ចឹមជ្រូក








## ក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា ចំកាត់

អាសយដ្ឋាន : គីឡូម៉ែត្រលេខ ២៣ ផ្លូវជាតិលេខ ៤ ភូមិចក ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល

ទូរស័ព្ទលេខ : ០២៣ ៣៦៧ ៣៣៩.៤២ ទូរសារលេខ : ០២៣ ៣៦៧ ៣៤០

# អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជាជាប្រទេសមួយកំពុងអភិវឌ្ឍន៍លើគ្រប់វិស័យដើម្បីអោយមានភាពជឿនលឿនដូចបណ្តាប្រទេសអភិវឌ្ឍន៍ដទៃទៀត  វិស័យកសិកម្មគឺជាវិស័យមួយដែលមានសារៈសំខាន់ ។

ដោយយោងទៅលើប្រជាជនកម្ពុជាភាគច្រើនប្រកបរបរកសិកម្ម នោះការចិញ្ចឹមជ្រូកគឺជាផ្នែកមួយមានសារៈសំខាន់ណាស់ ពីព្រោះសាច់ជ្រូកជាអាហារផ្គត់ផ្គង់ដល់មនុស្សទូទាំងពិភពលោក ។

នាឆ្នាំ១៩៩៦ ក្រុមហ៊ុន ស៊ី.ភី. បានមកធ្វើការវិនិយោគទុនលើវិស័យកសិ-ឧស្សាហកម្មនេះនៅព្រះរាជាណាចក្រកម្ពុជា ។

ក្រុមហ៊ុន ស៊ី.ភី. គឺជាអ្នកនាំមុខគេក្នុងផ្នែកកសិ-ឧស្សាហកម្ម ការចិញ្ចឹមសត្វ ដោយមានគោលនយោបាយសង្កត់ធ្ងន់ទៅលើគុណភាពផលិតផល , សេវាកម្មល្អ និង រក្សាភាពជាដៃគូជាមួយកសិករ ។

ចំពោះពូជជ្រូក ក្រុមហ៊ុនបាននាំចូលពីបរទេសដែលមានគុណភាពខ្ពស់ , មានរោងចក្រផលិតចំណីសត្វតាមមាត្រដ្ឋានបច្ចេកទេសត្រឹមត្រូវ , ការចិញ្ចឹមជ្រូកសម័យថ្មី និង ការចាត់ការផ្សេងៗដែលអាចនាំប្រជាកសិករឆ្ពោះទៅរកភាពជោគជ័យលើការចិញ្ចឹមជ្រូកបានយ៉ាងពិតប្រាកដ ។

ក្រុមហ៊ុនបានរៀបរៀងសៀវភៅនេះឡើងដើម្បីជាប្រយោជន៍ដល់កសិករក្នុងការចិញ្ចឹមជ្រូកប្រសិនបើមានការខុសឆ្គងក្រុមហ៊ុនសូមអភ័យទោសទុកជាមុន ។ បើមានការសង្ស័យ ឬ ឆ្ងល់លើចំណុចណាមួយ សូមទំនាក់ទំនងតាមរយៈដេប៉ូគ្រប់ខេត្ត ក្រុង ឬ ភ្នាក់ងារក្រុមហ៊ុនដែលបានត្រៀមខ្លួនជាស្រេចដើម្បីបំរើលោកអ្នកគ្រប់ពេលវេលា ។

ម.ភ.ឯ.ក AIDOC
Code: 241-05
Date:
Donated by:

**"ហៃ-ប្រូ" "ស៊ី.ភី." និង "ម៉ាក់" ជាចំណីសត្វគុណភាពល្អ**

# មាតិកា


**ការចិញ្ចឹមជ្រូកសាច់** ........................................ 1

ការជ្រើសរើសពូជ ........................................ 2

ចំណី និង ការប្រើប្រាស់ចំណី ........................................ 2

កម្មវិធីវ៉ាក់សាំង ........................................ 7

ការកសាងទ្រុង ........................................ 8

ការចាត់ការទូទៅ ........................................ 9

**ការចិញ្ចឹមមេជ្រូក** ........................................ 11

ការជ្រើសរើសទីតាំង និងការកសាងកសិដ្ឋាន ........................................ 11

ការចាត់ការត្រៀមទទួលមេជ្រូកថ្មី ........................................ 12

ការបង្កាត់ ........................................ 13

ការចាត់ការផ្តល់ចំណី ........................................ 14

កម្មវិធីវ៉ាក់សាំង ........................................ 18

ការចាត់ការទូទៅ ........................................ 18

ថ្នាំព្យាបាលជំងឺ ដែលជួបប្រទះញឹកញាប់ ........................................ 28


"ហៃ-គ្រូ" "ស៊ី.ភី." និង "ហក់" ជាចំណីសត្វគុណភាពល្អ

# ការចិញ្ចឹមជ្រូកសាច់

ការចិញ្ចឹមជ្រូកសាច់នៅអតីតកាល ចាប់ពីជ្រូកកើតរហូតដល់ទំងន់ 100 គ.ក្រ ត្រូវប្រើរយៈពេលក្នុងការចិញ្ចឹមប្រហែល 10-12 ខែ ហើយជ្រូកមានខ្លាញ់ច្រើន សាច់ក្រហមតិច ប្រើចំណីអស់ច្រើនលក់បានតំលៃថោក ប៉ុន្តែបច្ចុប្បន្ននេះការចិញ្ចឹមជ្រូកបានអភិវឌ្ឍន៍ទៅមុខជាច្រើនធ្វើអោយរយៈពេលនៃការចិញ្ចឹមខ្លីនៅសល់តែ 6 ខែដែលអាចទទួលបានទំងន់ 100គ.ក្រ មានសាច់ក្រហមច្រើន , ខ្លាញ់តិច លក់បានតំលៃខ្ពស់ និង ជាសេចក្តីត្រូវការរបស់ទីផ្សារ ។

ដើម្បីទទួលបានទូវភាព ជោគជ័យក្នុងការចិញ្ចឹមជ្រូកសាច់ត្រូវមានកត្តា5 យ៉ាងគឺ :

1 - ពូជល្អ

2 - ចំណី និង ការប្រើប្រាស់ចំណី

3 - វិធានការការពារជំងឺ

4 - ការកសាងទ្រុង

5 - ការចាត់ការទូទៅ

# ១. ការជ្រើសរើសពូជ

ជាការដឹងច្បាស់រួចមកហើយថា ការចិញ្ចឹមជ្រូកត្រូវមានការចាត់ការល្អ , ចំណីសត្វគុណភាពល្អ , ការការពារជំងឺត្រឹមត្រូវ និង ត្រូវមានពូជជ្រូកល្អផង ។ ជ្រូកសាច់ដែលល្អក្នុងពេលបច្ចុប្បន្ននេះគឺ កូនជ្រូកសាច់របស់ក្រុមហ៊ុន ស៊ី.ភី. ព្រោះមានការលូតលាស់លឿនងាយចិញ្ចឹម រឹងមាំ រយៈពេលការចិញ្ចឹមខ្លី , ខ្លាញ់តិច , សាច់ក្រហមច្រើន , អត្រាចំណីប្តូរសាច់ល្អមានន័យថា ស៊ី ចំណីអស់តិចតែធំលឿន ជាតំរូវការរបស់ទីផ្សារ លក់បានតំលៃខ្ពស់ លោកអ្នកអាចទំនាក់ទំនងទិញតាមរយៈសាខាដេប៉ូ និង ដេប៉ូរបស់ក្រុមហ៊ុនគ្រប់ខេត្តក្រុង ។



# ២. ចំណី និង ការប្រើប្រាស់ចំណី

## ២.១. ចំណី

ចំណីជាកត្តាសំខាន់បំផុតក្នុងការចិញ្ចឹមជ្រូកសាច់ ដើម្បីអោយលទ្ធផលល្អ ពីព្រោះថ្លៃចំណាយ60%នៃការចិញ្ចឹមគឺថ្លៃចំណី ។ ចំណីដែលល្អនាំអោយជ្រូកលូតលាស់លឿន ដូច្នេះហើយការជ្រើសរើសចំណីល្អមកអោយជ្រូកស៊ីជារឿងសំខាន់ណាស់ កសិករត្រូវពិចារណាទៅលើ ប្រូតេអ៊ីន វីតាមីន , ធាតុរ៉ែរបស់ចំណីនោះ ព្រោះចំណីស៊ីចូលទៅដើម្បីកសាងសាច់និងចំណែកផ្សេងនៃរាងកាយ ។